# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៦៣ ប្រក-៩៧

## ប្រកាស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជ្រាប។**

-បានឃើញរដ្ឋធមនុញ្ញ នៃព្រះរាជណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស.រកប ០១៩៦,០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

-បានឃើញច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស.រក ប០១៩៧,០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧

**សម្រេច**

**ប្រការ** ១- បង្កើតគណៈកម្មការដុតបំផ្លាញគ្រឿងញៀនមួយ តាមខេត្ត ក្រុង ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-លោកព្រះរាជអាជ្ញារងបតុលាការខេត្ត-ក្រុង | ជាប្រធាន |
| ២-លោកប្រធានការិយាល័យបង្ក្រាបគ្រឿងញៀនខេត្ត-ក្រុង | ជាអនុប្រធាន |
| ៣-លោកតំណាងអភិបាលខេត្ត-ក្រុង | ជាសមាជិក |
| ៤-លោកស្នងការរងនគរបាលខេត្ត-ក្រុង និងជាប្រធាន ការិយាល័យកណ្តាលនគរបាលយុត្តិធម៌ ឬតំណាង | ជាសមាជិក |
| ៥-លោកក្រឡាបញ្ជីខេត្ត-ក្រុងម្នាក់ | ជាលេខាកត់ត្រា ។ |

**ប្រការ** ២-គណៈកម្មការនេះមានភារកិច្ចដុតបំផ្លាញគ្រឿងញៀន ថ្នាំញៀន សារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ នឹងគ្រឿងផ្សំទាំងឡាយ ដែលកំណត់ក្នុងតារាង I.II.III.IV ចែងលំអិតក្នុងឧបសម្ព័ន្ធ ដែលទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌតាមតុលាការខេត្ត-ក្រុង ។

**ប្រការ** ៣-ក្រោយការដុតបំផ្លាញ គណៈកម្មការខាងលើត្រូវបូកសរុបរបាយការណ៍នៃគ្រប់ដំហាន នៃការអនុវត្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**ប្រការ** ៤-អស់លោកជាសមាជិកគណៈកម្មការដូចចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ។

**ប្រការ** ៥-ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

ចម្លងជូន

-ក្រសួងមហាផ្ទៃ
-នាយកដ្ឋានបង្ក្រាបគ្រឿងញៀន
-ស្នងការនគរបាលខេត្ត-ក្រុង
-អភិបាលខេត្ត-ក្រុង
-ប្រធានតុលាការកំពូល
-មហាអយ្យការអមតុលាការកំពូល
-ប្រធានសាលាឧទ្ធរណ៍
-មហាអយ្យការអមសាលាឧទ្ធរណ៍
-ប្រធានតុលាការខេត្ត-ក្រុង
-មហាអយ្យការអមតុលាការខេត្ត-ក្រុង
ឯកសារ